**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៥ ប្រក.ជល

# ប្រកាស

## ស្តីពី

## ការផ្ទេរក្របខណ្ឌមន្ត្រីរាជការ

### ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ៥៧០ មស.គ្ររ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១.-**

ផ្ទេរក្របខណ្ឌមន្ត្រីរាជការចំនួន ០៧រូប ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម | **មូល សារិទ្ធិ** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២. លោក | **ម៉ម ដាតារ៉ា** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៣. លោក | **គន ដារ៉ា** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៤. លោក | **សែន វិសាល** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៥. លោក | **ម៉ុម មុនី** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

៦. លោក **ម៉ាន គីណាល់** ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៧. លោកស្រី **ឌីណា ម៉ូនីកា** ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងបរិស្ថាន។

**ប្រការ២.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានឯកសារអេឡិចត្រូនិចនិងព័ត៌មានវិទ្យា ប្រធាននាយដ្ឋានអាស៊ាន ប្រធាននាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងបរិស្ថាន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងបរិស្ថាន
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ